**ឧបសៅសង្ហា**



# ពន្ធុធាតុ នៃនយោយបាការបរទេស របស់សហរដ្ឋអាមេរិក



ពិនិត្យអំពីព្រឹត្តិការណ៏សំខាន់ៗមាននៅលើពិភពលោក

## មាតិការឿង


**សេចក្តីផ្តើម**......2
**កម្លាំងចលករ នៃ អាមេរិក**......2
« **ពន្ធុធាតុ** » (ADN) **របស់សហរដ្ឋអាមេរិក**......5
**សេចក្តីសន្និដ្ឋាន**......12

## សេចក្តីផ្តើម

យើងដឹងថា សហរដ្ឋអាមេរិក ជាមហាអំណាចតែមួយគត់ ដែលមានលទ្ធភាព អាចធ្វើអន្តរាគមន៍យោធា លើពិភពលោក ដោយឥតចាំបាច់ពឹងពាក់ប្រទេសណាមួយឡើយ។ អនុភាព នៃសហរដ្ឋអាមេរិក មិនត្រឹមមានតែ ក្នុងវិស័យយោធា តែវាមានស្ទើរតែគ្រប់វិស័យ ដែលគេ តែងសម្គាល់ នូវអនុភាពនោះ ក្នុងរូបភាពបីយ៉ាងគឺ :

អេប៉ូល (Apple), ហូលីវូត (Hollywood), និង ហាវារដ៍ (Harvard)។ រួមសេចក្តីមកគឺ : បច្ចេកទេសជាន់ខ្ពស់ ផ្នែកការឲដំណឹងរហ័ស, វប្បធម៌ប្រជាករ និង ឧត្តមការសិក្សា។ រូបភាពទាំងបីនេះ បានជ្រាបចូលទៅក្នុង គំនិតប្រជាពលរដ្ឋនៅលើពិភពលោក ហើយគេតែងទុកវា ជាយោងសំរាប់សម្គាល់ នូវ ភាពទំនើប និង ជឿនលឿន របស់សង្គមនីមួយៗ ក្នុងសាកលលោកនេះ។ តើឥទ្ធិពលនេះ កើតមកពី សហរដ្ឋអាមេរិក ធ្វើនយោបាយចក្រពត្រនោះឬ ?

## កម្លាំងចលករ នៃ សហរដ្ឋអាមេរិក

ប្រជាពលរដ្ឋអាមេរិកាំងភាគច្រើន បានជ្រើសរើស លោក បារ៉ាក់ អូបាម៉ា (Barak Obama) កូនកាត់ស្បែកខ្មៅ ជា

ប្រធានាធិបតី នៃសហរដ្ឋអាមេរិក ពីរអាណត្តិ[1]។ យើងឃើញថាទោះបី ធ្លាប់មានច្បាប់បែងចែក សម្បុរស្បែក យ៉ាងតឹងរឹង នៅសហរដ្ឋអាមេរិក តែនៅក្នុងចរន្ត នៃចិត្តគំនិត របស់ប្រជាពលរដ្ឋអាមេរិកាំង វាមាន ការវិវត្តន៍ទៅរក ការអោយតម្លៃ ដល់មនុស្សជាតិ ដោយយកមូលដ្ឋាន សេរីភាព ជាសាកល នៅលើពិភពលោក ជាខ្លឹមសារនៃសង្គមអាមេរិកាំង។ ការណ៍នេះ បញ្ជាក់អោយឃើញថា សង្គមមនុស្ស មានការដូរ នូវទម្រង់, ស្ថានភាព នៃមនុស្សធម៌ ទៅរកគោលដៅថ្មី សំរាប់ការរីកចំរើន នៃមនុស្សជាតិជានិច្ច។ លោក Alexis de Tocqueville បានសរសេរថា :

*ការលូតលាស់ បន្តិចម្តងៗ នៃសមភាព ជាថៃដន្យល្អ ឬដែលមកពីបុព្វទេព។ វាមានលក្ខណៈគោលជាច្រើន ដូចជា : សាកល, ឋិតថេរ, របូតរៀងរាល់ថ្ងៃពីអំណាចមនុស្ស ; គ្រប់ព្រឹត្តិការណ៍ ក៏ដូច មនុស្សទាំងអស់ បានយក ការលូតលាស់នេះ មកប្រើប្រាស់។ តើនឹងមានប្រាជ្ញាដែរឬទេ ដោយគិតថា ដំណើរនៃសង្គមមួយ ដែលមានកំណើតដើមសែនឆ្ងាយ វាអាចនឹងត្រូវផ្អាក ក្នុងជំនាន់មួយបាន ? តើគេអាចគិតថា ក្រោយពីបានកំទិច នូវសក្តិភូមិបាន និងបរាជ័យ នៃមហាក្សត្រទាំងឡាយ, លទ្ធិប្រជាធិបតេយ្យ វា*

[1] ឆ្នាំ ២០០៩ ដល់ ២០១៧។

*ថយក្រោយ នៅចំពោះមុខ ពួកគហបតី និង សេដ្ឋី ? តើវាឈប់ក្នុងកាលឥឡូវនេះ នៅពេលដែលវាកំពុងខ្លាំងណាស់ ហើយសត្រូវកំពុងខ្សោយណាស់ ?*

សំណេរនេះ ជាការសង្ខេប នៃចិត្តគំនិត (pensée) នៃជនជាតិអាមេរិកាំង ដែលយក សេរីភាពរបស់ខ្លួន សំរាប់បំរើនូវការលូតលាស់ នៃមនុស្សជាតិ។ តែការរិកចំរើននេះ មិនមែនគ្រាន់តែមាន ប្រជាកម្លាំង តែម្នាក់ឯង វាត្រូវមានផងដែរ នូវច្បាប់ល្អៗបន្ថែមទៀត ទើបវាអាចកើតមានកម្លាំងកុសល នៃប្រជាជាតិ ផ្អែកលើ នីតិរដ្ឋ ដោយយក គោលការណ៍ នៃអធិបតេយ្យភាពរបស់ប្រជាជន ជាមូលដ្ឋានច្បាប់ ដូចគេធ្លាប់ស្គាល់ ប្រយោគពិសេសមួយឃ្លាថា : ច្បាប់ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ និង ដើម្បីប្រជាពលរដ្ឋ។ គោលការណ៍នេះឯង ជាអង្គហេតុពិត ដែលបង្កើត នូវប្រជាជាតិអាមេរិកាំង រួចអាចកសាង នូវមហាអំណាច នៃលទ្ធិប្រជាធិបតេយ្យ នៅលើពិភពលោក ដែលទុក ប្រាជ្ញា ជាវត្ថុធាតុ នៃការលូលាស់ ក្នុងគោលការណ៍ : វិទ្យាសាស្ត្រ ជាមធ្យោបាយ សំរាប់ដឹកនាំ, បញ្ញា ជាកម្លាំងសង្គម និង អ្នកចេះដឹង ជាអ្នកដឹកនាំជាតិ។

សួរថា តើគោលការណ៍នេះ វាមាននៅក្នុងនយោបាយការបរទេស របស់សហរដ្ឋអាមេរិក ដែរឬទេ ?

ដើម្បីឆ្លើយសំណួរនេះ យើងគួរស្វែងដឹង អំពី « ពន្ធុធាតុ » របស់សហរដ្ឋអាមេរិក តើវាមានបែបណា ? ពន្ធុធាតុ នេះ បើនិយាយឲស្រួលយល់ គឺគ្មានអ្វីក្រៅពី ការស្វែងដឹងអំពី « ទំនៀមទម្លាប់ » នៃនយោបាយ ការបរទេស នៃសហរដ្ឋអាមេរិក ក្នុងវិស័យទំនាក់ទំនង អន្តរជាតិនោះឯង។

យើងដឹងថា ក្នុងនយោបាយ ការបរទេស នៃសហរដ្ឋអាមេរិក មាន ពន្ធុធាតុ ពីរផ្ទុយគ្នា គឺ ធាតុជា :

« សារហាវិនិយម[2] » (Messianisme) និង « ឯកានិយម » (Isolationnisme)។

លើចំណុចនេះ, លោក Alain Minc, នយវិទូបារាំងសែសល្បីល្បាញម្នាក់ បានសរសេរថា[3] : បើនិយាយអំពី **សារហាវិនិយម**, សហរដ្ឋអាមេរិក មានមនោសញ្ចេតនា ជាអ្នកសង្គ្រោះសត្វលោក (L'arche de Noé) តាមបញ្ជារបស់ព្រះ ពីគ្រោះថ្នាក់ទឹកជំនន់មួយ ដែលនឹងមានកើតឡើង។ សហរដ្ឋអាមេរិក : ជាប្រជាជាតិមួយ យោងតាមការយល់ឃើញរបស់លោក Thomas Jefferson[4] មានជំនឿថា ខ្លួនអាចនឹង បង្កើតឋានសួគ៌ នៅលើឋានមនុស្ស ដែលជាស្នាដៃ

[2] សារហាវិនិយម : អ្នកនាំសារនិយម។

[3] ឈ្មោះសៀវភៅរបស់លោក Alain Minc : ព្រលឹង នៃប្រជាជាតិ (l'âme des nations)។

[4] Thomas Jefferson : ជា ប្រធានាធិបតី នៃសហរដ្ឋអាមេរិក ទី៣ (១៨០១-១៨០៩) ។

របស់មនុស្សលោក (លើកលែងតែ ពួកមនុស្សខ្ញុំគេ), ជាបេសកកម្ម នៃអារ្យធម៌ ដែលមានជាប់ ជាមួយ « វាសនាពិសេស » ក្នុងករណីយកិច្ច បង្កើត នូវពិភពលោកថ្មីមួយ ដែលមាន ពាណិជ្ជកម្ម និង សេរីភាព របស់បុគ្គលនីមួយៗ ជាគ្រឹះរបស់សង្គមមនុស្ស។ បើយោងតាមសំដី ដ៏ឆ្នើមមួយរបស់លោក John Adams[5], សហរដ្ឋអាមេរិក ត្រូវបញ្ចេញ នូវគុណសម្បត្តិរបស់ខ្លួន អោយបានពេញលេញ ដើម្បីឲប្រទេសដ៏ទៃទៀត យកប្រទេសខ្លួន ជាគំរូតាមសមានចិត្តរបស់គេ។

តែបើនិយាយ អំពីជាតុជា **ឯកានិយម** វិញ, សហរដ្ឋអាមេរិក មានបំណងការពារ នូវអ្វី ដែលខ្លួនបានបង្កើតឡើងសំរាប់ប្រជាជាតិខ្លួន, លោក Washington[6] ថ្លែងថាដោយទុកការបង្កើតមានជោគជ័យ : « ក្នុងពេលមួយ ប្រទេសយើង នឹងក្លាយជា មហាអំណាចមួយ ដែលគ្មាន នរណាមួយ អាចនឹងធ្វើឲយើង ខ្លាចបាននោះឡើយ »។ តែការចែកដាច់គ្នា រវាងអំណាច ប្រធានាធិបតី និង សភា (Congrès) អាចនាំឲ សហរដ្ឋអាមេរិក គ្មានមហិច្ឆិតានយោបាយ សង្កិតសង្កន់ប្រទេសដ៏ទៃ, គ្មានទម្លាប់ជាប្រពៃណី ក្នុងវិស័យយោធា វាយប្រហារប្រទេសដ៏ទៃ ដើម្បី

[5] John Adams : ជាប្រធានាធិបតី នៃសហរដ្ឋអាមេរិក ទី២ (១៧៩៧-១៨០១) ។

[6] George Washington : ជាប្រធានាធិបតី ទី១ នៃសហរដ្ឋអាមេរិក (១៧៨៩-១៧៩៧) ។

យកមកដាក់ នៅក្រោមការត្រួត្រា របស់ខ្លួន និង មិនព្រមឈរក្នុងជួរ ពីការបង្ខិតបង្ខំ។ ក៏ប៉ុន្តែ តាមការយល់ឃើញរបស់នយវិទូ មួយចំនួនថា ដោយទាញយកឧទាហរណ៍ ដែលមានកើតឡើងក្នុងទ្វីបអឺរ៉ុប គេទុករបៀបបែងចែកអំណាច នៅសហរដ្ឋអាមេរិក គឺសំរាប់តែការពារប្រយោជន៏ផ្ទាល់ របស់សហរដ្ឋអាមេរិក មុនគេបង្អស់ ដូចពាក្យស្លោកនយោបាយរបស់លោក ត្រាំ នោះដែរ។ តែស្មារតីនេះ ចំពោះសហរដ្ឋអាមេរិក គឺកើតមានឡើងតាំងដើមដំបូង នៃប្រវត្តិសាស្ត្រ របស់ខ្លួន ព្រោះដោយសារប្រទេសខ្លួន ធ្លាប់មានការសម្លាតខ្លាំង ពីសំណាក់ទ្វីបអឺរ៉ុប, តើវាមិនមែនជាទម្រង់ នៃការសងវេរនោះឬ ? ការមិនទុកចិត្តលើ ទ្វិបអឺរ៉ុបនេះ នាំបង្កើត នូវលទ្ធិនយោបាយមួយ ក្នុងកំឡុងឆ្នាំ ១៨៨២-៨៣ មានឈ្មោះថាលទ្ធិមុងរ៉ូ (Monroe), លទ្ធិនេះ ជាការបង្ហាញជាដំបូង នូវការមិនព្រមរបស់សហរដ្ឋអាមេរិក នៅចំពោះមុខ គ្រប់ការប៉ុនប៉ងជាថ្មី របស់ប្រទេសអឺរ៉ុបណាមួយ ចង់បង្កើតអាណានិគម នៅលើទឹកដីអាមេរិក ទាំងពីរ (អាមេរិកខាងជើង និង អាមេរិកឡាទិន ឬ ខាងត្បូង)។ សហរដ្ឋអាមេរិក ចាត់ទុកអន្តរាគមន៏ប្រទេសអឺរ៉ុប ក្នុងអឌ្ឍគោលបស្ចឹម (hémisphère Ouest) ជាអំពើឈ្លានពានមកលើសហរដ្ឋអាមេរិក តែម្តង។ ក្នុងលទ្ធិមុងរ៉ូ (Monroe) នេះហើយ ដែលសហរដ្ឋអាមេរិក បានគំរាមចំពោះ ព្រះចៅ

ណាប៉ូលេអុង ទី៣ (Napoléon 3) ក្នុងសង្គ្រាម បារាំង ជាមួយនឹង មិញសិក (Mexique) នៅលើដែនដី មិញសិក ដែលបិត នៅក្នុងអឌ្ឍគោលបស្ចឹម។ ការគំរាមនេះ បាន បង្ខំ ឲព្រះចៅណាប៉ូលេអុង ទី៣ ដកកងទ័ពបារាំង ចេញ ពីប្រទេសមិញសិក ដោយអាម៉ាស់មុខយ៉ាងខ្លាំង។

បើយើងធ្វើការសង្ខេប នូវសំណេររបស់លោក Alain Minc, យើងអាចសន្និដ្ឋានបានថា នយោបាយការបរទេស របស់ សហរដ្ឋអាមេរិក មានលក្ខណៈពីរ ផ្ទុយគ្នាស្រឡះ : សំរាប់ អំណាចនីតិប្រតិបត្តិ, អាមេរិក តែងមានសេចក្តីប្តេជ្ញា ជួយការពារ ចំពោះអ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យ នៅ លើពិភពលោក ដោយប្រើកម្លាំងយោធា ឬ នយោបាយ ចេញមុខ ទប់ទល់នឹង ការគំរាមកំហែង ពីសំណាក់កម្លាំង ណាមួយ មកលើអ្នកប្រជាធិបតេយ្យនិយម, តែសំរាប់ អំណាចនីតិបញ្ញតិវិញ អាមេរិក តែងតែមាន ការប្រុង ប្រយ័ត្នជានិច្ច ក្នុងការប្រើកម្លាំងយោធាក្តី នយោបាយក្តី នៅក្រៅដែនដីរបស់ខ្លួន។ នៅពេលណា គេយល់ឃើញថា អន្តរាគមន៍របស់គេ អាចនាំ នូវផលមិនល្អដល់គេ គេ ឥតមាន ការរួញរានឹង បង្ខំអោយរដ្ឋាភិបាលគេ បញ្ឈប់ អន្តរាគមន៍នោះភ្លាម។ ដូច្នេះ នយោបាយ នៃការបរទេស របស់សហរដ្ឋអាមេរិក ជានយោបាយមួយ ហាក់បីដូចជា

ផ្ទុយគ្នា (oxymoron[7]) រវាងប្រធានាធិបតី និង សភាទាំងពីរ របស់សហរដ្ឋអាមេរិក។

យើងអាចយកឧទាហរណ៍ សង្គ្រាមអាមេរិកាំង នៅកូរ៉េ និង វៀតណាម មកបង្ហាញអំពី នយោបាយអាមេរិកកាំង ក្នុងការប្រយុទ្ធ ចេញមុខ ការពារ លទ្ធិប្រជាធិបតេយ្យ ប្រឆាំងនឹង លទ្ធិកុម្មុយនិស្ត ដោយសួរជាសំណួរថា ហេតុអ្វីបានជាមានប្រសិទ្ធិភាពនៅប្រទេសកូរ៉េ ហើយ បរាជ័យនៅវៀតណាម ? សង្គ្រាមនៅវៀតណាម ជាសង្គ្រាមមួយដែលមាន មតិអន្តរជាតិភាគច្រើន យល់ឃើញថាជា អំពើអយុត្តិធម៌ សំរាប់ប្រជាជនយួន ដោយសារអំពើអាស្រូវរបស់របបសៃង៉ុង (Saigon) ដែលជាមូលហេតុ នាំអោយប្រជាពលរដ្ឋអាមេរិកាំង ឈប់គាំទ្រដល់ អន្តរាគមន៍យោធារបស់ខ្លួននៅវៀតណាម ទោះបីជា អន្តរាគមន៍ក្នុងបេសកកម្ម ប្រើ « អំពើល្អ ប្រឆាំងនឹង អំពើអាក្រក់ » ក៏ដោយ។ នៅពេលមួយ ដែលមារយាទ របស់សម្ពន្ធមិត្រ វាអាប់អោនជាងសត្រូវទៅទៀត, ដូច្នេះ ទោះបីរដ្ឋាភិបាលខំលើកអំពី គុណប្រយោជន៍ នៃនយោបាយអាមេរិកាំងក្នុងសង្គ្រាមនោះបែបណាក៏ដោយ ក៏ពុំអាចឈ្នះ មនោសញ្ចេតនា នៃមតិសាធារណៈជន ប្រឆាំងនឹងសង្គ្រាមនោះបានដែរ។ អាស្រ័យហេតុនេះ បានជា អាមេរិកាំង ដកខ្លួន

7 របៀបប្រើពាក្យពីរ មានន័យផ្ទុយគ្នា នាំអោយមានអនុភាពចម្លែក។

ចេញពីសង្គ្រាមនៅវៀតណាមក្នុងពេលនោះ។ តែជាការ អភ័ព្វណាស់ ចំពោះស្រុកខ្មែរយើង ក្នុងសង្គ្រាម នៃ សាធារណរដ្ឋខ្មែរ ប្រឆាំងនឹងការឈ្លានពានដែនដីខ្មែរ ពី សំណាក់កងទ័ពយួនកុម្មុយនិស្ត ដែលមានខ្មែរក្រហមជា បរិវា ព្រោះការដកនេះ នាំអោយប្រជាពលរដ្ឋខ្មែរ ទទួលថ្ម បាក់ ដោយសារតែ មតិអន្តរជាតិ និង មតិសាធារណៈអា មេរិកាំង លែងគាំទ្រ សង្គ្រាមការពារបរិបូរភាពទឹកដីខ្មែរ និង ការកសាង របបលទ្ធិប្រជាធិបតេយ្យសេរី នៅកម្ពុជា ដោយយល់ឃើញថា សង្គ្រមនៅស្រុកខ្មែរ វាគ្រាន់តែជាការ បន្ត សង្គ្រាមរបស់អាមេរិកាំង នៅវៀតណាម តែ ប៉ុណ្ណោះ។ មួយវិញទៀត ចំពោះមតិសាធារណៈ អាមេរិកាំង ចាត់ទុក របបសាធារណរដ្ឋខ្មែរ ជារបបស្រួយ (régime friable) មានរូបភាព ជារបបទន់ខ្សោយ ជាទីបំផុត (régime anémiée) តាំងពីកំណើតកើតឡើងម្លេះ ហើយ ក្រិន លែងប្រែប្រួលកើត (un régime sclérosé)។ ដូច្នេះ នៅពេលណា របបនេះ ឈប់មានជំនួយពីសហរដ្ឋអាមេរិក គឺច្បាស់រលំជាពុំខាន។ ការយល់ឃើញបែបនេះ វាមាន កម្មវិបាកជាវិនាដកម្ម ដល់ប្រជាជាតិខ្មែរ គឺត្រូវ របប កុម្មុយនិស្តខ្មែរ ហៅ « ខ្មែរក្រហម » សម្លាប់ជនខ្មែរស្លូត ត្រង់ជាងពីរលាននាក់។ តើមារយាទ របស់ពួកខ្មែរក្រហម វាល្អបែបណាទៅ នៅមុនពួកវាឈ្នះសង្គ្រាម រហូតមហា អំណាចអាមេរិកាំង យល់ឃើញថា ពួកនោះ អាចជា របប

ជម្រើសជំនួស របបសាធារណរដ្ឋខ្មែរ បាន ? តើ ពួកអ្នកដឹកនាំយួនកុម្មុយនិស្ត មានមារយាទខ្ពង់ខ្ពស់ ជា ពួកអ្នកគោរព នូវអធិបតេយ្យភាព និង បូរណភាពទឹកដីរបស់ប្រជាជន និង ប្រទេស អ្នកជិតខាងខ្លួន ដូចយ៉ាងស្រុកខ្មែរ និង ស្រុកលាវ ? ស្រុកយួនកុម្មុយនិស្ត ម្សិលម៉ិញតាំងខ្លួន ជាជនរងគ្រោះ ពីសំណាក់ ចក្រពត្រអាមេរិកាំងដោយសន្ទត់ តែសព្វថ្ងៃ ក្លាយជាចក្រពត្រ នៅតណ្ហូចិនហើយអនុវត្ត នូវនយោបាយ បញ្ជូន ជនជាតិយួនរាប់លាននាក់ចូលមករស់ជាស្លាពរនៅក្នុងស្រុកខ្មែរ និងលាវ។

## សហរដ្ឋអាមេរិក ជាចក្រពត្រ ?

ដូចយើងបានបញ្ជាក់ខាងលើរួចហើយថា អំណាចចក្រសហរដ្ឋអាមេរិកបច្ចុប្បន្ន គឺមិនមែនបិតនៅលើ ការគ្របសង្កត់ លើពិភពលោក ក្នុងផ្នែកយោធា នោះឡើយ, អំណាចចក្រនោះ គឺបិតក្នុងផ្នែក នយោបាយ, សេដ្ឋកិច្ច, ពាណិជ្ជកម្ម, បច្ចេកទេស, គមនាគមន៍ (médiatique) និង វប្បធម៌។ អំណាចចក្រនេះ ជាលទ្ធផល នៃរបៀបអប់រំដ៏ខ្ពង់ខ្ពស់មួយ នៃប្រព័ន្ធមហាវិទ្យាល័យ ដែលឥតអាចប្រៀបធៀបបាន ព្រោះជា របៀបអប់រំមួយ នាំបង្កើតនៅក្នុងគំនិត នៃយុវជនអាមេរិកាំង នូវគំនិតប្រជាធិបតេយ្យសេរី, សេរីភាព, សមភាព រវាង ប្រជាពលរដ្ឋ ក្នុងសាកលលោក។ ដោយសារតែ គំនិត, ភ្លើង នៃមនោគតិ,

ជម្រៅ នៃចិត្តគំនិត ដាអំណោយ បានមកពីធម្មជាតិ ដោយថៃដន្យ ដែលជា ថាមពល បញ្ចេះគ្រឿងចក្រ នៃលទ្ធិប្រជាធិបតេយ្យ អោយដើរទៅមុខជានិច្ច។ របៀបអប់រំនេះហើយ ដែលជាកត្តា ដែលពុំអាចជំរុញសហរដ្ឋអាមេរិកឲក្លាយជាប្រទេសចក្រពត្របានឡើយ។

## សេចក្តីសន្និដ្ឋាន

ទោះបីលោក ត្រុម (Trump) ធ្វើនយោបាយ មានទំនោរទៅរក គំនិតជាតិនិយមយ៉ាងណាក៏ដោយ តែនយោបាយនេះ វាមិនឃ្លាតចេញពីពន្លុធាតុ និង គោលការណ៍ដើមនៃសហរដ្ឋអាមេរិក គឺ ឯកានិយម នោះឯង។ តែសង្រ្គាមសេដ្ឋកិច្ច ជាមួយ មហាចិន ក៏មានលាយធាតុ នៃ សារហារីនិយម និង ឯកានិយម ព្រោះជាសង្រ្គាម ការពារផលប្រយោជន៍សហរដ្ឋអាមេរិកផង និង សម្ពន្ធមិត្តអាមេរិកាំងផង ជាពិសេស នាបច្ចុបន្ននេះ នៅដំបន់សមុទ្រប៉ាស៊ីហ្វិក ដែលមហាចិន មានបំណង ពង្រាល នូវអនុត្តរភាពរបស់ចិន។ ការបង្កើត អង្គការពាណិជ្ជកម្មអន្តរជាតិ នៅឆ្នាំង ១៩៩៥ ដែលមានគោលដៅចម្បង គឺសំរាប់ ការពារប្រទេសទាំងឡាយ ជាសមាជិក ក្នុងការប្រកួតសេដ្ឋកិច្ចខ្លាំងក្លា នៅលើពិភពលោក វាហាក់បីដូចជាជ្រលួសបន្តិចដោយសារ មហាពិភពលោកកម្ម (hyperglobalisation) សព្វថ្ងៃនេះ និង មហិច្ឆតា ក្នុងតំបន់សេដ្ឋកិច្ចនីមួយៗ

ដូចយ៉ាង នៅដំបន់ អាស៊ី, អឺរ៉ុប និង អាមេរិក ហើយ
ដំបន់ទាំងឡាយនោះ សុទ្ធតែធ្វើនយោបាយពាណិជ្ជកម្ម
ការពារដំបន់ផង និង ការពារប្រយោជន៏ប្រទេសរៀងៗ
ខ្លួនផង ជួនកាលក្នុងនាម ជាអ្នកជាតិនិយម ដែលនាំ
អោយចលនាជាតិនិយម មានឥទ្ធិពលខ្លាំង នៅក្នុងប
ណ្តាល ប្រទេសអឺរ៉ុបមួយចំនួន ដែលគំរាមដោយផ្ទាល់ ទៅ
លើលទ្ធិប្រជាធិបតេយ្យ។ ក៏ដូចគ្នានៅប្រទេស អាស៊ី ដូច
យ៉ាងប្រទេសឥណ្ឌា ដែលជា ប្រទេសមួយ គេទុកជា
ប្រទេសប្រជាធិបតេយ្យធំមួយនៅក្នុងពិភពលោក ក៏សព្វ
ថ្ងៃ មាននិន្នាការ ទៅរកគំនិតជាតិនិយមឈានមុខដែរ។
ប្រទេសចិនប្រជាមានិត ជាប្រទេសកុម្មុយនិស្ត ក៏យក
គោលការណ៏ជាតិនិយម មកអនុវត្ត នៅពេលណាគោល
ការណ៏នោះ វាមានប្រយោជន៏ ដល់គណបក្សកុម្មុយ
និស្តផង និង អាជ្ញាធរផង នៅចំពោះមុខ មហាអំណាច
លោកខាងលិច ដែលនាំអោយ សហរដ្ឋអាមេរិក និង អឺរ៉ុប
មាន ទំនាស់ជាមួយចិន ជាពិសេស លើបញ្ហាសិទ្ធិមនុស្ស
និង ការការពារប្រយោជន៏ពាណិជ្ជកម្ម នៅក្នុងផ្សារផ្ទៃ
ក្នុងចិន។ នយោបាយចិននេះ វាប៉ះទង្គិច ទុលមុខនឹង
នយោបាយជាតិនិយម « សហរដ្ឋអាមេរិកមុនគេ » របស់
លោកប្រធានាធិបតី ត្រុម បង្កើតបានជាជម្លោះពាណិជ្ជ
កម្មខ្លាំងក្លា រវាង អាមេរិកាំង និង ចិន សព្វថ្ងៃនេះ ដូច
យ៉ាង ការតម្លើងពន្ធលើទំនិញចិន នាំចូលមកក្នុងសហ

រដ្ឋអាមេរិក ដើម្បី ឆ្លើយតបនឹង នយោបាយ ការពារនិយមរបស់ចិន។ តែនយោបាយរបស់លោក ត្រាំ នេះ ក៏ប៉ះពាល់ដល់ប្រយោជន៍ អឺរ៉ុប ដែលជាសម្ពន្ធមិត្ត ជាប្រវត្តិសាស្ត្រ របស់សហរដ្ឋអាមេរិក ដែលវានាំអោយ ប្រជាពលរដ្ឋអឺរ៉ុបមួយភាគធំ មានអារម្មណ៍ ប្រឆាំងនឹង អាមេរិក ហើយ ទុកជាប្រទេសចក្រពត្រាសេដ្ឋកិច្ច។ មួយវិញទៀត ការវិលត្រឡប់ របស់ប្រទេសរុស្សី មកក្នុងការប្រកួតអន្តរជាតិ ក្នុងវិស័យយោធា នាំអោយមាន ភាពតានតឹងបន្ថែម ក្នុងនយោបាយ នៃការបរទេសអាមេរិកាំង ជាពិសេស នៅក្នុងលោកអារ៉ាប់ ដូចយ៉ាងនៅប្រទេសស៊ើរីនិង ការកាន់កាប់ដំបន់ Crimée ដែលជាការឈ្លានពានពេញមុខរបស់រុស្សី ទៅលើប្រទេស Ukraine។

មហាចិន វាយប្រហារ ប្រព័ន្ធ នៃលទ្ធិប្រជាធិបតេយ្យសេរីថាជាប្រព័ន្ធ មិនអាចយកមកអនុវត្តនៅគ្រប់ទីកន្លែងបាន ព្រោះប្រទេសនីមួយៗ គេមានលក្ខណៈពិសេសផ្ទាល់ខ្លួន។ ចំណែក លោក ពូ ទិន ប្រធានាធិបតី នៃប្រទេសរុស្សី រិះគន់យ៉ាងខ្លាំងចំពោះ ពួកអ្នកដឹកនាំសេរីនិយមនៅសហគមអឺរ៉ុបថា ការបើកទ្វារ អោយជនអន្តោប្រវេសន៍ ចូលមករស់នៅ ជានយោបាយភាន់ច្រឡំ នាំអោយសហគមអឺរ៉ុប ជួបប្រទះ នូវវិបត្តសង្គម គ្រប់បែបយ៉ាង។ ចំពោះលោក នយោបាយល្អ គឺ ជាតិនិយម, រដ្ឋាភិបាលត្រូវគិតប្រយោជន៍ នៃប្រជាជនខ្លួនឯងជាប្រយោជន៍ធំ។

ម្យ៉ាងទៀត ចិនក្ដី រុស្ស៊ីក្ដី បដិសេធ នូវគោលការណ៍ នៃសិទ្ធិមនុស្ស មានលក្ខណៈតែមួយសំរាប់មនុស្សជាតិនៅលើពិភពលោក ព្រោះយល់ឃើញថា ប្រជាជាតិនីមួយៗ គេមានដើមកំណើត និង ការវិវត្តន៍ ខុសៗគ្នា។ ដូច្នេះ សិទ្ធិមនុស្សប្រាកដនិយម វាមាននៅក្នុងចិត្តគំនិត របស់ប្រជាតិនីមួយៗ មិនមែនជាសិទ្ធិ កើតចេញពីគំរូ ណាមួយហើយបង្ខំ អោយយកវាមកអនុវត្ត ទាំងឆៅនោះទេ។ ដូច្នេះ ពួកអ្នកដឹកនាំ ចិន និង រុស្ស៊ី បច្ចុប្បន្ន កំពុង វិលត្រឡប់ ទៅយកទស្សនៈបុរាណរបស់គេ មកលាយនឹងទស្សនៈសម័យ ដែលគេទុកជា តម្លៃប្រាកដនិយម នៃប្រជាជាតិគេ ដែលគ្មាននរណាមួយ អាចធ្វើអោយរង្គោះរង្គើងបានជាដាច់ខាត។ សួរថា តើ ពួកអ្នកដឹកនាំចិនកុម្មុយនិស្ត និង រុស្ស៊ីជាតិនិយម អាចនឹងប្តូរចរន្ត នៃមនុស្សជាតិ ដើរទៅរកតម្លៃសាកល របស់មនុស្សលោក បានដែរឬទេ ? ដូចអ្នកដឹកនាំ នៃមហាចិន គ្រាន់តែលើកយក នូវលទ្ធផលវិជ្ជមានមួយចំនួន នៃការអភិវឌ្ឍន៍ និង សន្តិភាពមិនទៀង មកធ្វើជាព័ស្តុតាង សំរាប់បង្ហាញ នូវនយោបាយ ត្រឹមត្រូវរបស់ខ្លួន ? ដូចសំនួររបស់លោក Alexis de Tocqueville សួរថា តើនឹងមានប្រាជ្ញាដែរឬទេ ដោយគិតថា ដំណើរ នៃសង្គមមួយ ដែលមានកំណើតដើមសែនឆ្ងាយវាអាចនឹងត្រូវផ្អាកក្នុងជំនាន់មួយបាន ?

តែការភាន់ប្រែ នៃលំដាប់អន្តរជាតិបច្ចុប្បន្ន នៅក្នុងពិភពលោក តម្រូវអោយ សហរដ្ឋអាមេរិក ស្វែងរកនយោបាយ ការបរទេសថ្មី ដើម្បី កាត់តម្រូវនឹងការចាំបាច់ ដែលកំពុងកើតឡើង, តែរក្សាគោលការណ៏ គ្មានក្រហែងជាដាច់ខាតគឺ សេរីភាព និង លទ្ធិប្រជាធិបតេយ្យដែលជា ពិន្ទុធាតុ នៃប្រជាជាតិអាមេរិកាំង។ ពួកអ្នកស្តាំនិយម តម្រូវអោយមានការកាត់បន្ថយពន្ធ និង អោយមានស្លាកស្នាម នៃការធ្វើអោយត្រឹមត្រូវតាមច្បាប់, រីឯពួកអ្នកឆ្វេងនិយមវិញ ទាមទារអោយមានការចំណាយច្រើនក្នុងវិស័យអប់រំ និង ហេដ្ឋារចនាសម្ព័ន្ធសាធារណ:។ តែពួកទាំងពីរ យល់ព្រមគ្នាថាត្រូវតែមាន ការផ្លាស់ប្តូរគំរូសេដ្ឋកិច្ច ក្នុងនាម គំនិតថ្មី នៃពិភពលោកកម្ម។ តែទោះយ៉ាងណាក្តី ត្រូវដឹងថា សេដ្ឋកិច្ច ជាកម្លាំង នៃធម្មជាតិដូច ខ្យល់ និង ទឹក ហើយត្រូវចារ នៅក្នុងគំនិតថា សរទេរដូវ ច្បាស់ជាមានបន្ត រហូតដល់ វស្សានរដូវ, ពោលថាពិភពលោក មានច្បាប់ធម្មជាតិ ជានិយតករ នៅក្នុងការអភិវឌ្ឍន៏ នៃវិទ្យាសាស្ត្រ, បើមនុស្សលោក ធ្វើអ្វីផ្ទុយស្រឡះ ពីដំណើរការ នៃធម្មជាតិហួសហេតុពេក វារមែងជួបប្រទះនឹង គ្រោះថ្នាក់ ក្នុងវិស័យបរិស្ថាន ជាពុំខាន។

ទោះបីគេចង់ ឬ មិនចង់ សហរដ្ឋអាមេរិក ស្ថិតនៅជានិច្ច ជាមហាអំណាចលទ្ធិប្រជាធិបតេយ្យ និង សេរីភាពហើយ បែប នៃការរស់នៅ របស់ជនអាមេរិកាំង នៅតែជា

ការស្រមៃមួយ នៃប្រជាជនភាគច្រើន នៅលើពិភពលោក។ ហើយ ប្រជាពលរដ្ឋ ដែលទទួលរងគ្រោះ ពីសំណាក់របបផ្តាច់ការ រមែងនឹកស្រមៃដល់ការអន្តរាគមន៍គ្រប់រូបភាព នៃសហរដ្ឋអាមេរិក ព្រោះនៅតែទុកមហាអំណាចអាមេរិកាំង ជាប្រទេស នៃសារហារីនិយម អាចនឹងសង្គ្រោះប្រជាពលរដ្ឋរងគ្រោះ និង ទន់ខ្សោយ ចេញពីអំណាចផ្តាច់ការ និង អំពើអយុត្តិធម៌។ តើនយោបាយរបស់លោកប្រធានាធិបតី ត្រុម សព្វថ្ងៃ មាននិន្នាការ ជាតិនិយម និង ឯកានិយម ជានយោបាយបោះបង់ នូវតួនាទី នៃសហរដ្ឋអាមេរិក ជាកងអាវុធហត្ថអន្តរជាតិ ដែរឬទេ ?